ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៤៥១០ សហវ.លទក

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០១៦

**គោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

**កម្មវត្ថុ:** ករណីសំណើសុំប្រគល់កិច្ចសន្យាជូននាយកដ្ឋានវិស្វកម្មនៃក្រសួងធនធានទឹក និងឧតុនិយមស្តីពីការងារស្តារប្រឡាយមេរលាំងជ្រៃខាងត្បូង ប្រវែង ១០.៧០០ម ស្ថិតនៅក្នុងស្រុកសំរោងទង និងស្រុកគងពិសី ខេត្តកំពង់ស្ពឺ (ជំហានទី២) ។

**យោង:** -លិខិតលេខ ១៨០២ សហវ.អថ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-កំណត់ហេតុចរចាថ្លៃ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ របស់ គល ក្រសួងធនធានទឹក និងឧតុនិយម
-លិខិតលេខ ៩៤៨ ធទឧ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ របស់ក្រសួងធនធានទឹក និងឧតុនិយម ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងធនធានទឹក និងឧតុនិយម ក្នុងការប្រគល់កិច្ចសន្យាជូននាយកដ្ឋានវិស្វកម្មនៃក្រសួងធនធានទឹក និងឧតុនិយម ដើម្បីធ្វើការងារស្តារប្រឡាយមេរលាំងជ្រៃខាងត្បូង ប្រវែង ១០.៧០០ម ស្ថិតនៅក្នុងស្រុកសំរោងទង និងស្រុកគងពិសី ខេត្តកំពង់ស្ពឺ (ជំហានទី២) ក្នុងតម្លៃសរុបចំនួន ៧.០១២.០០០.០០០រៀល (ប្រាំពីរបីលាន ដប់ពីរលានរៀលគត់)ជាតម្លៃកិច្ចសន្យា ។

ការផ្ទេរបន្តទៅឱ្យក្រុមហ៊ុនឯកជនត្រូវបានហាមឃាត់ដាច់ខាត ។ បើអង្គភាពរដ្ឋណាមួយគ្មានលទ្ធភាពធ្វើខ្លួនឯងបាន ត្រូវដកហូតប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តវិញ ។ ក្នុងករណីប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាប និងមានវិធានការអនុវត្តបន្តឱ្យបានសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានថវិកា
- នាយកដ្ឋានវិស្វកម្មនៃក្រសួងធនធានទឹក និងឧតុនិយម
- សាលាខេត្តកំពង់ស្ពឺ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តកំពង់ស្ពឺ
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798